Rattanak

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៧៣៤ កសក

# លិខិតអម

**គោរពជូន:** -ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង

| ល.រ | រាយមុខលិខិត | ចំនួន | សេចក្ដីផ្សេងៗ |
|---|---|---|---|
| ១ | -របាយការណ៍ស្ដីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំឆមាសទី១ ឆ្នាំ២០១៦** និងទិសដៅអនុវត្តបន្ត .............................. | ០១ច្បាប់ | "ដើម្បីជូនជ្រាប" --------- |

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០១៦

តប រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អគ្គលេខាធិការ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣)៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥)២៣-២១៧ ៣២០

Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆមាសទី១ ឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងឆមាសទី១ ឆ្នាំ២០១៦នេះ តាមការកត់សម្គាល់ឃើញថា មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយល្អបង្គួរនៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេស។ ប្រជាកសិករបានខិតខំជំរុញការបង្កបង្កើនផលស្រូវរដូវវស្សាយ៉ាងសស្រាក់សស្រាំ ដោយសម្រេចបាន ៤២,០២% គិតមកទល់ចុងខែមិថុនា ឆ្នាំ២០១៦នេះ។ ស្ទូងនិងព្រោះអនុវត្តបាន ១ ០៤០ ៧២៦ហ.ត នៃផែនការ២ ៤៧៦ ៤៤៦ហ.ត មានសភាពលឿនជាងឆ្នាំមុនចំនួន៣០ ៨១៨ហ.ត ស្មើនឹង៣,០៣% បើប្រៀបធៀបរយៈពេលដូចគ្នា។ ប្រជាកសិករបាននិងកំពុងបន្តខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាបព្រោះ និងដកស្ទូង ដើម្បីឱ្យទាន់រដូវកាលដាំដុះ ដោយអនុវត្តបច្ចេកទេសកសិកម្មសមស្រប។ ជាការកត់សម្គាល់ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មកំពុងមាននិន្នាការកើនឡើងដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវឌ្ឍន៍នៃយន្តូបនីយកម្មកសិកម្ម។ ក្រៅពីដំណាំស្រូវ ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម ក៏មានការកើនឡើងដែរបើប្រៀបធៀបនឹងឆ្នាំមុន។ ប៉ុន្តែនៅដើមខែមិថុនា ឆ្នាំ២០១៦នេះ ការងារបង្កបង្កើនផលរបស់ប្រជាកសិករនៅក្នុងខេត្តមួយចំនួនបានទទួលរងនូវការរាតត្បាតដោយសត្វដង្កូវហ្វូងធ្វើឱ្យប៉ះពាល់ដល់ដំណាំកសិកម្មមួយចំនួនដូចជា៖ ពោត សណ្តែកដី សណ្តែកបាយ ដំឡូងមី ល្ពៅ និងស្រូវជាដើម តែស្ថានភាពនេះបានធូរស្រាលវិញហើយដោយសារមានភ្លៀងធ្លាក់រាយប៉ាយល្អបង្គួរនៅគ្រប់តំបន់តាមរាជធានី ខេត្ត ពិសេសខេត្តដែលទទួលរងនូវផលប៉ះពាល់នេះ ហើយក្រសួងក៏បានចាត់វិធានការចុះអន្តរាគមន៍ទាន់ពេលវេលាផងដែរ។ សកម្មភាពគួរកត់សម្គាល់មួយទៀត គឺមន្ត្រីជំនាញរដ្ឋបាលព្រៃឈើបានបន្តកិច្ចសហការជាមួយគណៈកម្មការជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ចុះប្រតិបត្តិការត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើនៅតាមអធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤ តាមស្មារតីនៃសេចក្តីសម្រេច លេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ដែលសម្រេចបានសម្រាប់ឆមាសទី១ ឆ្នាំ២០១៦នេះ មានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវ


អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

(៤៧ ០២៤តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៣៧ ៤៦៣តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (៣៦ ១៦៤តោន) ប្រទេសបែលហ្ស៊ិកឈរលំដាប់ទី៤ (១៤ ៦១២តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៥ (១៤ ៥០៩តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៦ (១៤ ០៩៩តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៧ (១៣ ១០១តោន) ប្រទេសឆេកឈរលំដាប់ទី៨ (១១ ៣៣៦តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៩ (១០ ៦៨៣តោន) និង ប្រទេសហុងគ្រីឈរលំដាប់ទី១០ (៨ ៦១៤តោន)។

## ២ ផ្នែកកៅស៊ូ

បច្ចុប្បន្ននេះតម្លៃកៅស៊ូមាននិន្នាការងើបឡើងបន្តិចវិញ ប៉ុន្តែទោះជាយ៉ាងណាក្រោមកិច្ចសហការជាមួយសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ដែលបង្កើតឡើងដោយរដ្ឋាភិបាលនៃប្រទេសទាំង១១ រួមទាំងកម្ពុជាផង យើងសង្ឃឹមថាតម្លៃកៅស៊ូអាចនឹងកើនឡើងវិញ តាមរយៈការរិះរកវិធានការនានាប្រកបដោយស្ថិរភាព និងមាននិរន្តរភាពសម្រាប់ជាប្រយោជន៍ដល់អ្នកដាំកៅស៊ូ។ បន្ថែមលើនេះទៀតនោះ រាជរដ្ឋាភិបាលក៏បានសម្រេចចេញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូរួចហើយ។ ដោយឡែក សម្រាប់ឆមាសទី១ ឆ្នាំ២០១៦នេះ តម្លៃកៅស៊ូជាមធ្យមក្នុងរង្វង់១ ២០០ ទៅ ១ ២៥០ដុល្លារក្នុងមួយតោន។

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥០៨ | ៧៥៧ | ២៤១ | ១២០ |
| | សរុប I | ៥០៨ | ៧៥៧ | ២៤១ | ១២០ |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១២ ៦០៣ | ១៦ ០២៨ | ៥ ២២២ | ២ ៥២១ |
| ២ | ក្រុមហ៊ុន ស៊ីហ្វរ៉ាប់បើលីមីធីត (រតនគិរី) | ៧៩ | ២ ៤៩៨ | ១៥ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៩០ | ២ ១០១ | ៣៣០ | ២៤៦ |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ២ ៥៧៥ | ៥ ០៩៩ | ១ ១៨០ | ៧៧៦ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣ ៩៩៧ | ៨ ៦៦១ | ១ ១៤៣ | ៤៥៣ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វសែសស៍ (ស្នួល) | ១ ៧៤៥ | ៤ ៣៦៥ | ៥៤០ | ៤៦៦ |
| ៧ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ១ ៨៨២ | ៣ ៣៩០ | ១៦៨ | - |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៣២៧ | ៥ ៩២៤ | ២២០ | - |
| ៩ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៤ ០៣៥ | ៥ ៧៣១ | ១ ៣៥៧ | ៥៥៩ |
| | សរុប II | ៣១ ២៣៣ | ៥៣ ៧៩៧ | ១០ ១៧៥ | ៥ ០២១ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៥ ៧៣៥ | ១៨៤ ២៥២ | ៩ ៨៦៤ | ២ ៦២៦ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៦ ៤៩៦ | ១៤៩ ៨៥៣ | ៣៥ ០៤០ | ១៤ ២៨០ |
| | សរុប III | ៨២ ២៣១ | ៣៣៤ ១០៥ | ៤៤ ៩០៤ | ១៦ ៩០៦ |
| | សរុប I+II+III | ១១៣ ៩៧២ | ៣៨៨ ៦៥៩ | ៥៥ ៣២០ | ២២ ០៤៧ |

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ចុះពិនិត្យនិងព្យាបាលជំងឺកៅស៊ូនៅតាមបណ្តាក្រុមហ៊ុនមួយចំនួន

| ល.រ | ឈ្មោះរាជធានី-ខេត្ត | ចំនួនសត្តឃាតដ្ឋាន | | ចំនួនសត្វពិឃាត | | | |
|---|---|---|---|---|---|---|---|
| | | សត្តឃាតដ្ឋានស្របច្បាប់ | ពិឃាតប្រមូលផ្តុំ/ពិឃាតតាមផ្ទះ | គោ (ក្បាល) | ក្របី (ក្បាល) | ជ្រូក (ក្បាល) | មាន់ (ក្បាល) |
| ១ | ភ្នំពេញ | ១១ | | | | | |
| ២ | កណ្តាល | ២២ | | ២ ៣៦៥ | | ១៩ ៧២៥ | ៣៥៣ ៧៤០ |
| ៣ | កំពង់ស្ពឺ | ១១ | | ៣ ៨២៨ | | ១៦ ៩៧៨ | |
| ៤ | ព្រៃវែង | ១១ | | ១ ៦១៩ | ១៥ | ១៦ ១៣៧ | |
| ៥ | ស្វាយរៀង | ០៨ | | | | | |
| ៦ | កំពង់ឆ្នាំង | ១០ | | | | | |
| ៧ | ពោធិ៍សាត់ | ០៦ | | ១ ២៨៤ | ៧១ | ៩ ២៧៨ | |
| ៨ | បាត់ដំបង | ១៤ | | ៦ ៦៧៨ | ២១៨ | ២៩ ០៨៩ | |
| ៩ | បន្ទាយមានជ័យ | ១០ | | ២៣ ០០០ | ៦០០ | ៧៨ ០០០ | |
| ១០ | សៀមរាប | ៧ | | | | | |
| ១១ | កំពង់ធំ | ៦ | | ៣ ៤៦៤ | ៣២៥ | ១៣ ១៧៣ | |
| ១២ | ព្រះសីហនុ | ៣ | | | | | |
| ១៣ | កែប | ១ | | | | | |
| ១៤ | កំពត | ៥ | | ១ ៥២៩ | | ១៣ ២៤១ | ៦ ១៤០ |
| ១៥ | កោះកុង | ៣ | | | | | |
| ១៦ | ក្រចេះ | ៥ | | ២ ៨៧៧ | ១០៣ | ១៧ ២៩៨ | |
| ១៧ | ស្ទឹងត្រែង | ១ | | | | | |
| ១៨ | រតនគិរី | ៣ | | | | | |
| ១៩ | មណ្ឌលគិរី | ២ | | ៧១០ | | ២ ៤៣២ | |
| ២០ | ប៉ៃលិន | ១ | | | | | |
| ២១ | ឧត្តរមានជ័យ | ១ | | ១ ៥៤២ | | ៩ ៤៣២ | ៨ ១៥០ |
| ២២ | តាកែវ | ០ | ១៨ | | | | |
| ២៣ | កំពង់ចាម | ០ | | ២ ០២៣ | | ១២ ៣៣៧ | ១៣ ៣២៤ |
| ២៤ | ត្បូងឃ្មុំ | ០ | | ២ ៣៣៨ | ៤២ | ១២ ៤៥៥ | |
| ២៥ | ព្រះវិហារ | ០ | | | | | |
| សរុប | | ១៤១ | ១៨ | ៥៣ ២៥៧ | ១ ៣៧៤ | ២៤៩ ៥៧៥ | ៣៨១ ៣៥៤ |

- **ការងារនីតិកម្មនិងវិវាទ៖** ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ហើយក្រសួងកំពុងរៀបចំបោះពុម្ពផ្សព្វផ្សាយជាសាធារណៈឲ្យបានទូលំទូលាយ និងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់តាមអាទិភាព។

- ចុះទៅសិក្សាស្រាវជ្រាវនៅខេត្តកណ្តាល ខេត្តបាត់ដំបង និងខេត្តកំពត ជាលទ្ធផលប្រមូលបានសំណាកសរុបចំនួន១ ៣៦៧សំណាក ពីសត្វប្រចៀវ-ជ្រឹងចំនួន ៤៨៦ក្បាល ដើម្បីយកទៅធ្វើការវិភាគរកមេរោគដែលមាននៅក្នុងខ្លួនសត្វប្រចៀវ-ជ្រឹង

- ផ្តល់សត្វគោ៥ក្បាលជាចំណីដល់ត្មាតនៅខេត្តស្ទឹងត្រែង ក្រចេះ ព្រៃការពារមណ្ឌលគិរី និងព្រៃការពារព្រះវិហារ ដើម្បីធានាការរស់រានរបស់សត្វត្មាត និងធ្វើការសង្កេតតាមដាន

- ធ្វើការកត់ត្រា និងការពារសម្បុកសត្វត្រដក់តូចចំនួន ១១សម្បុក សត្វត្មាតចំនួន ១០សម្បុក សត្វរំពេទន្លេចំនួន១៧សម្បុក ត្រយ៉ងចង្កំកសចំនួន៣០សម្បុក នៅខេត្តស្ទឹងត្រែង ក្រចេះ និងសៀមប៉ាង។ ការពារសម្បុកសត្វដើម្បីធានាសុវត្ថិភាពពងកូន ពីព្រោះសម្បុកសត្វទាំងនេះងាយរងគ្រោះដោយសារការប្រមូលរបស់មនុស្ស និងការបំផ្លាញរបស់សត្វព្រៃ ហើយប្រភេទសត្វទាំងនេះជាប្រភេទជិតផុតពូជ ព្រមទាំងចុះអន្តរាគមន៍ជួយដល់ប្រជាពលរដ្ឋដែលទទួលរងការបំផ្លិចបំផ្លាញដោយសត្វដំរីលើផលដំណាំចំនួន១៨ករណីដែលមាន៣៤គ្រួសារ ទទួលរងការខូចខាតផលដំណាំមួយចំនួនរួមមាន ចេក ស្វាយចន្ទី ខ្នុរ ធុរេន ដំឡូងមី។ ក្រុមអភិរក្សក៏បានចុះសិក្សាស្រាវជ្រាវ និងប្រមូលសំណាកលាមកដំរីនៅជួរភ្នំក្រវាញនៅដំណាក់កាលទី៥ ដោយទទួលបានសំណាកលាមកដំរីចំនួន៣៧១សំណាក ក្នុងនោះ លាមកស្រស់មានចំនួន ២០៦សំណាក លាមកស្រស់បង្គួរមានចំនួន ១៣០សំណាក និងលាមកមិនស្រស់ ៣៥សំណាក សម្រាប់យកទៅវិភាគ DNA ដើម្បីកំណត់ចំនួនដំរីព្រៃនៅក្នុងជួរភ្នំក្រវាញ។

### ៤.៣ កសិដ្ឋានចិញ្ចឹម ការបន្ពាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ឆមាសទី១ ឆ្នាំ២០១៦នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាគឺ៖ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន១ ១៩៩ក្បាល សត្វកើតថ្មីចំនួន៥១ក្បាល ដោះលែងទៅព្រៃធម្មជាតិវិញចំនួន១ ០៤៦ក្បាល ជួសជុលទ្រុងសត្វចាស់ចំនួន៧៨០ម² ជួសជុលផ្លូវចំនួន៨៧ ៧៤០ម² អប់រំផ្សព្វផ្សាយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធចំនួន៩៦១នាក់ ស្ត្រីចំនួន៤៥៨

- ក្រុមល្បាតសហគមន៍ចំនួន ២៨នាក់ បានបន្តការងារល្បាតនៅតំបន់ដែនជម្រកសត្វក្រពើសំខាន់ៗចំនួន៥ គឺនៅអារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងជាច់ ស្ទឹងខៀវ និងអូរសោម(ខេត្តកោះកុង)បានប្រទះករណីបទល្មើសចំនួន១១ករណី

- ដោះលែងក្រពើចំនួន ៧ក្បាល នៅស្ទឹងខៀវ ឃុំបាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង

- ក្រុមហ៊ុនចំនួន ៦ បានគ្រប់គ្រងកសិដ្ឋានចំនួន ៧ ដែលមានស្វាក្តាមសរុបចំនួន ៥៥ ៥៧៧ក្បាល និងនាំចេញចំនួន៣ ២៦៤ក្បាល

- ក្រុមការងារអភិរក្សសត្វក្រពើកម្ពុជាបានចុះតាមដានរកឃើញក្រពើចំនួន១៣ដង ដែលបានចាប់ឧបករណ៍វិទ្យុសម្លេងនៅស្ទឹងខៀវតំបន់កោះប៉ោ ខេត្តកោះកុង។

### ៤.៤ ការខារដាំដើមឈើ

- ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូង បានធ្វើការឈូសឆាយដីទំហំ៣២៥ហិកតា និងបណ្តុះកូនឈើសរុបចំនួន៦០០ ០០០ដើម

- ចម្ការឈើដែលមានផ្ទៃដីទំហំ២ ១៩៣ហ.ត ស្ថិតនៅក្នុងស្ថានីយផ្សព្វផ្សាយស្តារព្រៃឈើទូទាំងប្រទេសដែលកំពុងពង្រឹងការយាមល្បាតដើម្បីទប់ស្កាត់ការរុករានហ៊ុមព័ទ្ធកាន់កាប់ដីព្រៃ និងទប់ស្កាត់ភ្លើងព្រៃ

- បណ្តុះកូនឈើគ្រប់ប្រភេទបានចំនួន១ ១៧៥ ៩១១ដើម និងចែកជូនប្រជាពលរដ្ឋដាំបានចំនួន២៦៨ ៨៥៤ដើម

- បណ្តុះកូនផ្តៅកបានចំនួន៣០ ០០០ដើម ដើម្បីធ្វើការអភិរក្សធនធានសេនេទិកតាមរយៈការបង្កើតចម្ការពូជលើផ្ទៃដីទំហំ១០ហ.ត នៅខេត្តព្រះសីហនុ

- បណ្តុះកូនគ្រញូងចំនួន២ ០០០ដើម ដើម្បីដាំបញ្ចូលទៅក្នុងតំបន់ប្រភពគ្រាប់ពូជឈើគ្រញូង ខេត្តសៀមរាប

- ក្រុមហ៊ុន ស៊ីងបាយអុចេក ជាដៃគូសហការដាំឈើជាមួយរដ្ឋបាលព្រៃឈើនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើបឹងចារ បានធ្វើការឈូសឆាយដីដាំឈើចំនួន៣០០ហិកតា និងបានបណ្តុះកូនឈើចំនួន ៦០០ ០០០ដើម

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន២៨ ៥០០តោន ស្មើនឹង១៩,០០% នៃផែនការ១៥០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១២ ៦៥៥តោន។

៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន៥៥ ៣៥០តោន ស្មើនឹង៥០,៣២% នៃផែនការ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន៣ ៨៥០តោន។

**៥.២ វារីវប្បកម្ម**

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន៦៩ ០៥០តោន ស្មើនឹង៤៧,៩៥% នៃផែនការ១៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន៥ ៥០០តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន១១៥ ០០០ក្បាល ស្មើនឹង៤៦,០០% នៃផែនការ២៥០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន២០ ៥០០ក្បាល

- ការភ្ញាស់កូនត្រីពូជ អនុវត្តបានចំនួនប្រមាណ៦០ ០០០ ០០០កូន ស្មើនឹង៣៣,៣៣% នៃផែនការ១៨០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួនប្រមាណ២៥ ០០០ ០០០កូន

- កិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំពិធីមច្ឆទិវា១ កក្កដា ឆ្នាំ២០១៦ នៅខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

**៥.៣ ការកែច្នៃផលនេសាទ**

- ផលនេសាទទឹកសាប អនុវត្តបានចំនួន២៦ ២០០តោន ស្មើនឹង៣១,៩៥% នៃផែនការ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៥ ៣០០តោន

- ផលនេសាទសមុទ្រ អនុវត្តបានចំនួន៥ ៨២៥តោន ស្មើនឹង៧២,៨១% នៃផែនការ៨ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន២២៥តោន

- ការផលិតទឹកត្រី អនុវត្តបានចំនួន៣៣ ០០០ ០០០លីត្រ ស្មើនឹង៦៦,០០% នៃផែនការ៥០ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៧ ០០០ ០០០លីត្រ។

**៥.៤ ការនាំចេញផលនេសាទ**

- ផលនេសាទស្រស់ អនុវត្តបានចំនួន៥ ០៥០តោន ស្មើនឹង៣៣,៦៧% នៃផែនការ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន២៥០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន២ ៨០០តោន ស្មើនឹង៥៦,០០% នៃផែនការ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន១០០តោន។

**៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស**

- សម្រាប់ឆមាសទី១ ឆ្នាំ២០១៦នេះ សំណុំរឿងបទល្មើសជលផលមានចំនួន១ ២៩៨ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន១ ១៨៥ករណី និងសមុទ្រចំនួន១១៣ករណី

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង២១ ៦០៥ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន២ ៨៧៤មាត់ បង្គោល/ចម្រឹងចំនួន៩ ៨៨៤ដើម ឧបករណ៍ឆក់ត្រីចំនួន១៧គ្រឿង សម្រាស់ចំនួន៩៥០ម៉ែត្រក្រឡា និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន១ ០៧៥គ.ក្រ

- បានផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន៨៥វគ្គ ដោយមានអ្នកចូលរួមចំនួន៣ ៤៩២នាក់ ក្នុងនោះស្ត្រីចំនួន៧១២នាក់

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យ និងមានវិធានការដើម្បីលុបបំបាត់

ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទ ក្នុងឆមាសទី១ចំនួន៥៥ច្បាប់ សរុបចំនួន២១៩ច្បាប់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការរៀបចំពិធីបុណ្យផ្សេងៗ និងការងារសន្តិសុខរួមរបស់ក្រសួង។

## ៩ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦ ៦៥២នាក់ នារីចំនួន១ ៣៩៩នាក់ ស្មើនឹង២១% រួមមាន៖
  + អង្គភាពថ្នាក់កណ្ដាលចំនួន៤ ០៤៤នាក់ ក្នុងនោះនារីចំនួន៨១៥នាក់ ស្មើនឹង២០%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២ ៦០៨នាក់ ក្នុងនោះនារីចំនួន៥៨៤នាក់ ស្មើនឹង២២%

- ចេញប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌមានចំនួន២៦នាក់ ក្នុងនោះបោះបង់ការងារមានចំនួន០៤នាក់ សុំលាឈប់ពីការងារចំនួន០៥នាក់ និងមរណភាពមានចំនួន១៧នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងមានចំនួន០៧នាក់ ផ្ទេរចូលក្រសួងមានចំនួន០៧នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន២១នាក់

- ត្រៀមរៀបចំការប្រឡងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី ដែលក្រសួងមុខងារសាធារណៈបែងចែកឱ្យមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានចំនួន៣៣៣នាក់

- ចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងមន្ត្រីកសិកម្មរាជធានី ខេត្ត លើ៣តំបន់

- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកពីការងារចំនួន៤៦នាក់ ក្នុងនោះឈប់សម្រាកប្រចាំឆ្នាំចំនួន២៨នាក់ ព្យាបាលជំងឺចំនួន០៤នាក់ និងសម្រាកលំហែមាតុភាពចំនួន១៤នាក់

- ចេញប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន១០៤នាក់

- ចេញប្រកាសឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញចំនួន៤៨នាក់

- ចេញប្រកាសដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈចំនួន១៣៤នាក់

- ចេញប្រកាសជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាចំនួន១០២៤នាក់

- បានរៀបចំការងារបណ្ដុះបណ្ដាលក្នុងប្រទេស និងក្រៅប្រទេសចំនួន១៨៩នាក់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្ដាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ១០ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានសម្របសម្រួលជាមួយលេខាធិការដ្ឋានអាស៊ានដើម្បីរៀបចំសិក្ខាសាលាថ្នាក់តំបន់នៃក្រុមការងារជំនាញបច្ចេកទេសអាស៊ានសម្រាប់រៀបចំគោលនយោបាយព្រៃឈើអន្តរជាតិ កិច្ចប្រជុំលើកទី១២ នៃក្រុមការងារបច្ចេកទេសអាស៊ាន កិច្ចប្រជុំលើកទី៤ នៃក្រុមប្រឹក្សាស្បៀងបម្រុងសង្គ្រោះបន្ទាន់អាស៊ានបូក៣ ដែលមានសមាជិកចូលរួមមកពីបណ្ដាប្រទេសអាស៊ានទាំង១០

- បានរៀបចំទិវាពិភពលោកប្រយុទ្ធប្រឆាំង និងរហោឋានកម្ម ឱនភាពដី នៅភូមិត្រពាំងឈូក ឃុំពោធិ៍អង្គ្រង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ

- បានបញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីទៅចូលរួមសិក្ខាសាលា ទស្សនកិច្ចនិងវគ្គបណ្ដុះបណ្ដាលនៅក្នុងប្រទេស និងក្រៅប្រទេសចំនួន២៨៩នាក់

- បានរៀបចំថវិកាកម្មវិធីសម្រាប់នាយកដ្ឋានឆ្នាំ២០១៧

- បានសម្របសម្រួលជាមួយ CDC លើសំណើបញ្ជូនគម្រោង Improvement of Commune Level Agriculture Extension System Rural Development ទៅភាគី(KOICA) កូរ៉េ

- ធ្វើសំណើទៅរាជរដ្ឋាភិបាលដើម្បីស្នើសុំសិទ្ធិប្រទានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្ដីពីការបង្កើតមជ្ឈមណ្ឌលអាស៊ានសម្រាប់សុខភាពសត្វ និងជំងឺស៊ូណូស

- បានសម្របសម្រួលទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីផ្ដល់គម្រោងផែនការរំកិល ២០១៦-២០១៨ សម្រាប់អនុវត្តផែនការសកម្មភាពមេគង្គ-ជប៉ុន និងយុទ្ធសាស្ត្រក្រុងតូក្យូថ្មី២០១៥

ជាមួយគណៈប្រតិភូសាកលវិទ្យាល័យ Ghent ប្រទេសបែលស៊ិក និង សាកលវិទ្យាល័យ កាន់ថូ ប្រទេសវៀតណាម អំពីការអភិវឌ្ឍន៍មហាវិទ្យាល័យជលផល បានទទួលគណៈប្រតិភូសាកលវិទ្យាល័យ Tsukuba ជប៉ុនមកធ្វើផ្សព្វផ្សាយអាហារូបករណ៍ទៅបន្តការសិក្សានៅប្រទេសជប៉ុន និងទទួលនិស្សិតបារាំងម្នាក់មកធ្វើកម្មសិក្សារយៈពេល២ខែ នៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ។ ថែមពីនេះទៀត សាកលវិទ្យាល័យបានប្រជុំពិភាក្សាជាមួយ USIAD និងសាកលវិទ្យាល័យ Kansas State សហរដ្ឋអាមេរិក អំពីគម្រោងបង្កើត Center of Excellence for Sustainable Agriculture Intensification and Nutrition នៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ។ ទន្ទឹមនឹងនេះ សាកលវិទ្យាល័យបានទទួលសម្ភារមន្ទីរពិសោធន៍ថ្មី របស់មហាវិទ្យាល័យវិទ្យាសាស្ត្រសត្វ និង វិស្វកម្មកសិកម្ម តាមរយៈគម្រោង HEQIP របស់ក្រសួងអប់រំ យុវជន និងកីឡា ហើយសាកលវិទ្យាល័យបានបញ្ជូនថ្នាក់ដឹកនាំនិងមន្ត្រីសាស្ត្រាចារ្យចំនួន៦រូប និង និស្សិត៥រូប ទៅបំពេញបេសកកម្មនៅបរទេស។ សាកលវិទ្យាល័យបានបិទវគ្គកម្មសិក្សារយៈពេល៨សប្តាហ៍ របស់គរុនិស្សិតចំនួន៧នាក់ មកពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

តាមការកត់សម្គាល់ឃើញថា មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយជាបង្គួរនៅតាម បណ្តាខេត្ត-រាជធានីទូទាំងប្រទេស។ រីឯស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ សម្រេចបាន ៤២,០២% លឿនជាងឆ្នាំមុន៣៩ ៨១៨ហ.ត (ស្មើនឹង៣,០៣%) បើប្រៀបធៀបរយៈពេលដូចគ្នា។ ជារួម ស្ថិតក្នុងបរិការណ៍នេះ ក្រសួងបានដាក់ចេញជាវិធានការជំរុញការងារបង្កបង្កើនផលស្រូវវស្សាឆ្នាំ២០១៦នេះ ដើម្បីណែនាំដល់អង្គភាពក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្តទាំងអស់ឱ្យយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវវស្សាតាមរយៈការផ្តល់អនុសាសន៍ដល់កសិករឱ្យអនុវត្តផលិតកម្មដំណាំស្រូវតាមលក្ខណៈប្រពលវប្បកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ដោយពិចារណាទៅលើយន្តការនិងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗ តាមការចាំបាច់ និងចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងករណីមានការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ ទន្ទឹមនឹងនេះ ក៏បានជំរុញចាត់វិធានការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាព ព្រមទាំងជីកស្តារស្រះ ប្រឡាយ អាងស្តុកទឹក រក្សាទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាព ពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ ជាមួយគ្នានេះ ក្រសួងក៏បានរៀបចំជាគណៈកម្មការនិងក្រុមការងារតាមការចាំបាច់ដើម្បីចូលរួមដោះស្រាយឱ្យបានទាន់ពេលវេលាលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ជាពិសេស ចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព ព្រមទាំងបន្តសហការអនុវត្តអនុក្រឹត្យលេខ៣៤អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតួនាទីនិងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ចនិងការគ្រប់គ្រងក្នុងក្របខ័ណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការឆ្នាំ២០១៦នេះ។

កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាន និងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាព រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២ និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

**៤ ផ្នែកជលផល** :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តតាមដាននិងសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការទប់ស្កាត់បទល្មើសនេសាទ ពិសេសក្នុងរដូវបិទនេសាទឆ្នាំ២០១៦

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៦ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ក៏បានគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀប និងកំពង់ចាមឱ្យទៅជាវិទ្យាស្ថានវិញ

- បន្តរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា តាមស្មារតីនៃលិខិតលេខ១៣០៣ សជណ.សរ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

- បន្តសហការអនុវត្តអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតួនាទីនិងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ចនិងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងតំបន់ការពារនិងអភិរក្សព្រៃឈើនិងជលផល ជាពិសេសការផ្ទេរតំបន់ព្រៃការពារ តំបន់អភិរក្សព្រៃឈើចំនួន១៣កន្លែង និងព្រៃផ្តល់ផលចំនួន៥កន្លែង ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទៅក្រសួងបរិស្ថានគ្រប់គ្រង និងបានផ្ទេរតំបន់សម្បទានដីសេដ្ឋកិច្ចចំនួន៧៣កន្លែង ពីក្រសួងបរិស្ថាន ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់គ្រងបន្ត តាមរយៈអនុក្រឹតលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៦

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ គោលការណ៍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្ម មានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស ស្តង់ដារ និងការផលិតសម្រាប់ឈានទៅរកការធ្វើសមាហរណកម្មពាណិជ្ជកម្មផលិតផលកសិកម្មក្នុងបរិបទនៃសាកលភាវូបនីយកម្ម៕

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**